ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
## ស្តីពី
## លទ្ធផលការងាររបស់ព្រឹទ្ធសភា
## ប្រចាំខែកក្កដា ឆ្នាំ២០១៨

នៅក្នុងខែកក្កដា ឆ្នាំ២០១៨នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅៈ

**១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បានៈ**

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ ចំនួន ០១លើក និងសម័យប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញជាកិត្តិយសក្នុងព្រះរាជពិធីបុណ្យរុក្ខទិវា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណា **ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅស្ថានីយ៍ដាំកូនឈើថ្មរូង ភូមិព្រៃកអំពិល ឃុំកោះតូច ស្រុកទឹកឈូ ខេត្តកំពត

-អញ្ជើញជាអធិបតីក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមាព្រះវិហារថ្មី និងសម្ពោធឆ្លងសមិទ្ធផលនានា នៅវត្តព្រះពុទ្ធនិព្វាន ស្រុកគងពិសី ខេត្តកំពង់ស្ពឺ

-អញ្ជើញជាអធិបតីក្នុងពិធីកាត់ឫសសីមាព្រះវិហារ និងសម្ពោធឆ្លងសមិទ្ធផលនានា ក្នុងវត្តព្រៃក្តួច ឃុំត្រពាំងក្រញូង ស្រុកត្រាំកក់ ខេត្តតាកែវ

-អញ្ជើញចុះសួរសុខទុក្ខចាស់ជរា និងប្រជាពលរដ្ឋតាមខ្នងផ្ទះ នៅក្នុងបូរីសូនីភូមិឬស្សីកែវទី១ សង្កាត់ស្ទឹងមានជ័យទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៣០ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២៩ច្បាប់ ។

**១.២.ឯកឧត្តម នៃ ប៉ុណា អនុប្រធានទី១ព្រឹទ្ធសភា បាន :**

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ និងជ្រាបជាព័ត៌មានចំនួន៣៧ច្បាប់ ។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន :**

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ នីតិកាលទី៤ ចំនួន០១លើក និងសម័យប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

-អញ្ជើញចូលរួមក្នុងព្រះរាជពិធីបុណ្យរុក្ខទិវា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅស្ថានីយ៍ដាំកូនឈើថ្មរូង ភូមិព្រៃកអំពិល ឃុំកោះតូច ស្រុកទឹកឈូ ខេត្តកំពត

-អញ្ជើញសួរសុខទុក្ខលោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ព្រមទាំងបានឧបត្ថម្ភថវិកាសម្រាប់ចាក់គ្រួសក្នុងបរិវេណអនុវិទ្យាល័យព្រះពុទ្ធ ស្ថិតក្នុងឃុំព្រះពុទ្ធ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល

-អញ្ជើញជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ តាមបណ្តាស្រុកនានាក្នុងខេត្តកណ្តាលចំនួន០៧លើក

-អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធឧបដ្ឋានសាលា និងសមិទ្ធផលនានា ក្នុងវត្តក្តីទំពែក ភូមិស្វាយដំណាក់ ឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្តាល

-អញ្ជើញចូលរួមពិសាអាហារសាមគ្គី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៦០នៃទំនាក់ទំនងការទូត និងសហប្រតិបត្តិការកម្ពុជា-ចិន នៅមជ្ឈមណ្ឌលកោះពេជ្រ

-អញ្ជើញពិសាអាហារសាមគ្គី ដែលបានរៀបចំដោយសមាគមមិត្តភាពកម្ពុជា-ចិន និងស្ថានទូតនៃសាធារណរដ្ឋប្រជាមានិតចិន នៅភោជនីយដ្ឋានឡៅទីហ្វាង

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៣៤ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៣ច្បាប់ ។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ នីតិកាលទី៤ ចំនួន០១លើក:**

១.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៩ ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនស្នេថេក ខូអិលធីឌី

២.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៩ ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនខេមបូឌាអ៊ិនធើរណេស្យូណាលអ៊ិនវេស្តមែន ឌីវេឡុបមែនគ្រុបៗ

**៣. សម័យប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៤ ចំនួន០១លើក** :

១.ពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនស្នេថេក ខូអិលធីឌី

២.ពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនខេមបូឌា អ៊ិនធើរ-ណេស្យូណាល អ៊ិនវេស្តមែន ឌីវេឡុបមែនគ្រុប ។

**៤.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា** :

ក្នុងខែកក្កដានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម:

**៤.១. មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

-អញ្ជើញចុះជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំស្រុក ក្រុមប្រឹក្សាឃុំជ្រៃឃ្មុំ ឃុំព្នៅទី១ ឃុំព្នៅទី២ និងឃុំរំលេច សរុបចំនួន២៥នាក់ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពចែករំលែក និងផ្តល់ព័ត៌មានស្តីពី នីតិវិធីនៃការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ នីតិ-កាលទី៦ នៅសាលាឃុំជ្រៃឃ្មុំ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង ។

**៤.២. មុខងារតំណាង**

-បានទទួលពាក្យបណ្តឹងចំនួន០៣ករណី កំពុងពិនិត្យសិក្សាចំនួន០៣ករណី ព្រមទាំងទទួលការឆ្លើយតបអំពីការដោះស្រាយពាក្យបណ្តឹងពីស្ថាប័នពាក់ព័ន្ធចំនួន ០២ករណី និងឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០២ករណី

-អញ្ជើញចុះជួបសំណេះសំណាល និងសួរសុខទុក្ខ ព្រមទាំងសម្ពោធដាក់ឱ្យប្រើប្រាស់អណ្តូងទឹកស្អាតជូនប្រជាពលរដ្ឋ សិស្សានុសិស្សប្រើប្រាស់ នៅសាលាបុណ្យ ភូមិត្រពាំងត្រប់ សង្កាត់បឹងធំ ខណ្ឌពោធិ៍សែនជ័យ និងសាលាបឋមសិក្សាអ្នកឧកញ៉ាមហា-កត្តី **ហ៊ិន នាង** អន្ទង់ក្វាន នៅភូមិអន្ទង់ក្វាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

-អញ្ជើញចូលរួមប្រជុំពិភាក្សាអំពីផែនការអនុវត្ត និងត្រៀមលក្ខណៈរៀបចំកិច្ចប្រជុំប្រចាំឆ្នាំលើកទី២៧ នៃសភាអាស៊ី-ប៉ាស៊ីហ្វិច (APPF)

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគបានប្រជុំពិនិត្យ និងពិភាក្សាផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៨ និងផែនការយុទ្ធសាស្ត្រចុងឆ្នាំ២០១៨

-អញ្ជើញចូលរួមប្រជុំរវាងក្រុមមិត្តភាពព្រឹទ្ធសភាជាមួយសភាសហភាពសហព័ន្ធរុស្ស៊ីស្តីពី ការផ្សព្វផ្សាយសេចក្តីសម្រេចចាត់តាំងក្រុមមិត្តភាពព្រឹទ្ធសភាជាមួយសភាសហភាពសហព័ន្ធរុស្ស៊ី និងពិភាក្សាការងារអំពីសំណើសុំជួបរបស់ក្រុមមិត្តភាពសភារុស្ស៊ី-កម្ពុជា

សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះទៅតាមបណ្តាខេត្ត ក្រុង រាជធានី-ភ្នំពេញចំនួន៤៥០លើក ដើម្បីជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខ

ប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានាតាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព សិក្សាឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៨៩លើក ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

-ឯកឧត្តម ***ជា ដេដ្ឋ*** ឯកឧត្តម ***គង់ សារាជ*** ឯកឧត្តម ***យ៉ង់ សែម*** និងឯកឧត្តម ***ម៉ែន ស៊ីផាន់*** អញ្ជើញចូលរួមមហាសន្និបាតលើកទី៤៤របស់សភានិយាយភាសាបារាំង (APF) នៅសភាកេបិច ខេត្តកេបិច នៃប្រទេសកាណាដា

-ឯកឧត្តម ***ឈិត គឹមយាត*** អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ទទួលបន្ទុកការងារសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព នៅទីក្រុងពីសស្ទូរីបេ នៃសាធារណរដ្ឋសាយព្រឹស

-លោកជំទាវ ***ទី បូរ៉ាស៊ី*** និងឯកឧត្តម ***ជា ដេដ្ឋ*** អនុញ្ញាតឱ្យលោក Maxime Jonanet និងលោក Jean Castosini អ្នកស្ម័គ្រចិត្ត និងជាកម្មសិក្សាការីជនជាតិបារាំង នៃការិយាល័យហ្វ្រង់កូហ្វូនី ព្រឹទ្ធសភា ចូលជួបសម្តែងការគួរសម និងជម្រាបលា

-ឯកឧត្តមបណ្ឌិត ***ម៉ុង ឫទ្ធី*** អញ្ជើញទទួលជួបលោក Yamamoto Masaki ចុះពិនិត្យមើលការចាប់ផ្តើមអនុវត្តគម្រោងសាងសង់ទីលានប្រណាំងរថយន្ត និងបង្ហាត់បង្រៀនឱ្យចេះប្រើប្រាស់រថយន្តច្រើនប្រភេទ ។ ក

ថ្ងៃព្រហ ១២កើត ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូនៈ

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសា